00854290

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 19 / 10 / 2012
ម៉ោង (Time/Heure) : 15:15
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

E223/2

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

សាធារណៈ / Public

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ ២០១២

**ជូនចំពោះ:** ភាគីនៃសំណុំរឿង ០០២

**ពី:** ចៅក្រម និល ណុន, ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន:** លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ:** សវនាការដេញដោលលើឯកសារនាពេលខាងមុខ និងចម្លើយតបទៅនឹងអនុស្សរណៈរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសំណើរបស់ អង្គជំនុំជម្រះសាលាដំបូងស្នើសុំកំណត់អត្តសញ្ញាណនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ប្រើប្រាស់នៅសវនាការ (ឯកសារ E208/4) និងសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំកែតម្រូវបញ្ជីភស្តុតាងគាំទ្រ (ឯកសារ E223)

១. បន្ថែមពីលើអនុស្សរណៈរបស់អង្គជំនុំជម្រះលេខ E233 ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១២ នាពេលដ៏ខ្លីខាងមុខអង្គជំនុំជម្រះសាលាដំបូងនឹងកំណត់កាលបរិច្ឆេទសវនាការបន្ថែម ដើម្បីទុកលទ្ធភាពឲ្យមានការជំទាស់ចំពោះឯកសារសេសសល់ក្នុងសំណុំរឿង ០០២/០១ ដែលអង្គជំនុំជម្រះពុំទាន់បានផ្តល់ឱកាសទៅភាគីដើម្បីលើកឡើងករណីនៃការជំទាស់ ដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ អង្គជំនុំជម្រះក៏សូមផ្តល់ការណែនាំមួយចំនួនបន្ថែមទាក់ទងនឹងចម្លើយជាលាយលក្ខណ៍អក្សរដែលភាគីបានដាក់ដោយអនុលោមតាមសេចក្តីសម្រេចលេខ E96/7។

*ក. ការលើកទឡ្ហីករណ៍ដោយផ្ទាល់មាត់ទាក់ទងនឹងឯកសារសេសសល់ទាំងអស់នៅ សវនាការ*

២. នាពេលដ៏ខ្លីខាងមុខ អង្គជំនុំជម្រះសាលាដំបូងនឹងចេញសេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារនានារបស់សហព្រះរាជអាជ្ញាដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងឧបសម្ព័ន្ធ ក៦ ដល់ ក១១ និង ក១៤ ដល់ ក២០ ព្រមទាំងឯកសារនានាដែលភាគីផ្សេងទៀតបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយដែលត្រូវបានពិចារណានៅក្នុងសវនាការដេញដោលលើឯកសារកាលពីពេលមុន។ ភាគច្រើននៃឯកសារដែលភាគីបានដាក់មកទល់នឹងពេលបច្ចុប្បន្នក្នុងលក្ខណៈជាឯកសារពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ នឹងជាកម្មវត្ថុនៃការលើកទឡ្ហីករណ៍តទល់ដោយផ្ទាល់មាត់ ដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។ ឯកសារនឹងត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ហើយនឹងផ្តល់ចំណាត់ថ្នាក់ឯកសារ លេខ E ក្នុងករណីដែលអង្គជំនុំជម្រះយល់ឃើញថាឯកសារទាំងនេះបានបំពេញលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងអនុវិធាន នៃវិធានផ្ទៃក្នុងនេះ។

៣. បន្ទាប់ពីមានការអាននៅក្នុងសវនាការនូវកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលទាក់ទងនឹងចំណុចអង្គហេតុទាំងនេះ អង្គជំនុំជម្រះសាលាដំបូងក៏នឹងធ្វើសវនាការដេញដោលលើភស្តុតាងពាក់ព័ន្ធនឹងផ្នែកអង្គហេតុចុងក្រោយនៃសំណុំរឿង ០០២/០១ ដែលមានដូចជារចនាសម្ព័ន្ធយោធា និងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១ និងទី ២) (ឯកសារ E236/1)។ កាលពីថ្ងៃទី ០៨ ខែ តុលា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងបន្ថែមទៅភាគីថាខ្លួននឹងពង្រីកវិសាលភាពនៃការជំនុំជម្រះដើម្បីដាក់បញ្ចូលការចោទប្រកាន់មួយចំនួនទាក់ទងនឹងកន្លែងសម្លាប់មនុស្សនៅទួលពោធិជ្រៃ ប៉ុន្តែអង្គជំនុំជម្រះនឹងពុំពិចារណាអំពីការពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/ ០១ ឱ្យលើសពីនេះទៀតឡើយ (ឯកសារ E163/ 5)។

៤. អនុលោមតាមសេចក្តីសម្រេចមុនៗរបស់អង្គជំនុំជម្រះ ភាគីត្រូវបានស្នើសុំឱ្យបង្ហាញដោយមិនឱ្យហួសថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១២ ឡើយ ថាតើឯកសារបន្ថែមណាខ្លះពីបញ្ជីឯកសារដើមរបស់ភាគី (ដូចជាបញ្ជីនានាដែលបានដាក់កាលពីខែ មេសា ឆ្នាំ ២០១១) ពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវធ្វើសវនាការស្តីពីការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១ និងទី ២) និង

កន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ។ បញ្ជីបន្ថែមដែលពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវធ្វើសវនាការទាក់ទងនឹងកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃ និងការផ្លាស់ទីលំនៅប្រជាជនខាងលើនេះ អាចដាក់បញ្ចូលឯកសារនានាពីសំណុំរឿង និងឯកសារក្នុងបញ្ជីឯកសារនៃខែ មេសា ឆ្នាំ ២០១១ របស់ភាគី។ ភាគីមិនចាំបាច់ដាក់បញ្ចូលឯកសារដែលមានរួចហើយនៅក្នុងបញ្ជីឯកសារក្រោយៗ (បញ្ជីឯកសារនៃខែ កក្កដា ឆ្នាំ ២០១១) របស់ភាគីពាក់ព័ន្ធនឹងចំណុចអង្គហេតុមុនៗ ដែលបានធ្វើសវនាការក្នុងសំណុំរឿង ០០២/០១ រួចហើយនោះទេ ព្រមទាំងឯកសារដែលត្រូវបានលើក យកមកធ្វើជាឯកសារយោងនៅត្រង់ជើងទំព័រនៃកថាខណ្ឌនៃដីកាដំណោះស្រាយពាក់ព័ន្ធ (ដូចដែលបានបញ្ជាក់នៅក្នុងឯកសារ E124/7.3 ដែលឆ្លុះបញ្ចាំងអំពីការធ្វើការកែប្រែបន្ទាប់ពីមានអនុ- ស្សរណ: E163/5) ឬឯកសារទាំងឡាយណាដែលអង្គជំនុំជម្រះបានដាក់ចំណាត់ថ្នាក់ឯកសារ E3 រួចហើយ។ ដើម្បីសម្រួលដល់ការពិនិត្យមើលឡើងវិញរបស់អង្គជំនុំជម្រះ ភាគីក៏ត្រូវផ្តល់លេខយោងនៃឯកសារនីមួយៗពីបញ្ជីខែ មេសា របស់ភាគីផងដែរ។

៥. នាពេលដ៏ខ្លីខាងមុខ អង្គជំនុំជម្រះមានបំណងធ្វើសវនាការទាក់ទងនឹងឯកសារ និងប្រភេទនៃឯកសារទាំងអស់ដែលសេសសល់ ដែលភាគីបានស្នើសុំដាក់ក្នុងសំណុំរឿង ០០២/០១ ប៉ុន្តែពុំទាន់មានការលើកទឡ្ហីករណ៍តទល់។ ឯកសារទាំងនោះមានជាអាទិ៍៖

- ឯកសារទាំងអស់ដែលត្រូវបានលើកយកមកធ្វើជាឯកសារយោង នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១ និងទី ២) និងកន្លែងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃតួយ៉ាងដូចជាកថាខណ្ឌ ២០៥-២០៥, ៦៥៨-៧១១, ៥៧៥-៥៧៧, ១១០៥-១១១៣, ១១៥១-១១៥៣, ១៣៧៥ និង ១៣៨៥ ។
- ឯកសារនានាដែលអាចឲ្យទទួលយកបាននាពេលបច្ចុប្បន្ន បន្ទាប់ពីមានសេចក្តីសម្រេចលើឯកសារថ្មីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E190, ដូចដែលបានចង្អុលបង្ហាញក្នុងឯកសារ E190.1 និង E190/2.1) ឬឯកសារនានាដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅពេលក្រោយមកទៀតដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលអង្គជំនុំជម្រះពុំទាន់បានផ្តល់ឱកាសទៅភាគីដើម្បីលើកទឡ្ហីករណ៍តទល់ (ឧទាហរណ៍ ឯកសារ E21 6/3 និងឯកសារ E172/24/4)។
- សេចក្តីថ្លែងទាំងឡាយដែលបានបង្ហាញនៅក្នុងកថាខណ្ឌ ២៨ នៃឯកសារ E96/7 (ឯកសារ ឬភស្តុតាងផ្សេងៗដែលត្រូវបានយោងត្រង់ជើងទំព័រនៃដីកាដំណោះស្រាយត្រង់ផ្នែកពាក់ព័ន្ធ) ដែល

បានទទួលចំណាត់ថ្នាក់ E3 រួចហើយ ប៉ុន្តែពុំទាន់ត្រូវបានអង្គជំនុំជម្រះពិចារណានៅក្នុងសវនាការដេញដោលលើឯកសារមុនៗ

- ឯកសារផ្សេងៗណាមួយដែលកាលពីពេលកន្លងទៅ ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីនានាដែលភាគីបានដាក់ដោយអនុលោមតាមកថាខណ្ឌ ១២ ដល់កថាខណ្ឌ ១៣ នៃដីកា E9 របស់អង្គជំនុំជម្រះសាលាដំបូង ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ និងដែលអង្គជំនុំជម្រះពុំទាន់បានផ្ដល់ឱកាសទៅភាគីដើម្បីលើកទឡ្ហីករណ៍តទល់។

៦. នៅពេលដែលភាគីបានបង្ហាញឯកសារទាំងអស់ពីបញ្ជីឯកសារដើមរបស់ភាគី ដែលត្រូវបានចាត់ទុកជាឯកសារពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវធ្វើសវនាការដែលមានដូចជា ការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១ និងដំណាក់កាលទី ២) និងកន្លែងសម្លាប់មនុស្សនៅទួលពោធិជ្រៃរួចហើយនោះ សវនាការដើម្បីអនុញ្ញាតឱ្យមានការលើកទឡ្ហីករណ៍តទល់ទាក់ទងនឹងឯកសារទាំងនេះ នឹងត្រូវកំណត់កាលបរិច្ឆេទនាពេលសមស្របខាងមុខ។

### *ខ. ចម្លើយជាលាយលក្ខណ៍អក្សរដែលភាគីបានដាក់ បន្ទាប់ពីមានសេចក្ដីសម្រេច E96/7*

៧. ដោយយោងទៅលើចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៃចម្លើយជាលាយលក្ខណ៍អក្សរ និងតម្លៃជាភស្តុតាងតិចតួចដែលអាចត្រូវបានផ្ដល់ទៅចម្លើយទាំងនោះ ដោយពុំមានសក្ខីកម្មរបស់ម្ចាស់ចម្លើយ អង្គជំនុំជម្រះបានស្នើសុំឱ្យភាគីបញ្ជាក់ថាតើចម្លើយណាខ្លះ ដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ព្រមទាំងបញ្ជាក់ពីគោលបំណងនៃភស្តុតាង ឬប្រភេទនៃភស្តុតាងនីមួយៗដែលភាគីបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយមិនឱ្យហួសថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១២។ ក្នុងករណីដែលភស្តុតាងនេះមានចំនួនច្រើន ឬត្រួតជាន់គ្នា ភាគីត្រូវបានស្នើសុំឱ្យពិចារណាអំពីការស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនូវភស្តុតាងគំរូ ដែលតំណាងឱ្យប្រភេទនៃភស្តុតាងនីមួយៗ (ជំនួសឱ្យឯកសារ ឬចម្លើយទាំងអស់ក្នុងប្រភេទ នីមួយៗ) (ឯកសារ E96/7, កថាខណ្ឌ ៣៥)។

៨. កាលពីថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១២ មេធាវីការពារជនជាប់ចោទ ខៀវ សំផន បានចោទប្រកាន់ថា "មានការក្លែងបំភ័ន្ត" ជុំវិញកាលៈទេសៈដែលអ្នកស៊ើបអង្កេត ក.ស.ច.ស បានស្ដាប់ចម្លើយសាក្សីម្នាក់។ មេធាវីខាងលើបានជំទាស់ទៅនឹងចំនួនដ៏ច្រើននៃឯកសារ ដែលសហព្រះរាជអាជ្ញាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដោយអនុលោមតាមសេចក្ដីសម្រេច E96/7

00854294

។ ការចោទប្រកាន់ខាងលើគឺនៅពេលដែលមេធាវីការពារក្តីពិនិត្យពិចារណាម៉ត់ចត់ ទាក់ទិននឹងភាពអាចទុកចិត្តបាននៃកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយរបស់ ក.ស.ច.ស និងការពិនិត្យពិចារណាម៉ត់ចត់ជាងនេះទៀតនៅពេលដែលចម្លើយទាំងនោះពាក់ព័ន្ធនឹងបុគ្គលនានាដែលពុំទាន់ត្រូវបានកោះហៅឱ្យផ្តល់ភស្តុតាងនៅសវនាការ (ឯកសារ E223, កថាខណ្ឌ ៦-៧ (ដោយបានធ្វើការកត់សម្គាល់ថាចម្លើយចំនួនប្រមាណជា ២៤១៦ ត្រូវបានដាក់ដោយសហព្រះរាជអាជ្ញា))។ ភាគច្រើននៃចម្លើយទាំងនេះត្រូវបានចោទប្រកាន់ទៀតថា ពុំស្ថិតក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ និងពុំទាន់ត្រូវបានបកប្រែ។ ដោយយោងទៅតាមភាពចាំបាច់ដែលមេធាវីការពារក្តីត្រូវពិនិត្យចម្លើយទាំងនេះ មេធាវីការពារក្តីចោទប្រកាន់ថាការដាក់ឯកសារក្នុងចំនួនដ៏ច្រើននេះ ប៉ះពាល់ដល់កិច្ចខិតខំរបស់អង្គ-ជំនុំជម្រះសាលាដំបូងដើម្បីធានាបាននូវការសន្សំសំចៃតាមផ្លូវតុលាការ និងការគាំពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះដោយឆាប់រហ័ស (ឯកសារ E233, កថាខណ្ឌ ៩-២២)។ មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំឱ្យអង្គជំនុំជម្រះបង្គាប់ឱ្យសហព្រះរាជអាជ្ញាកែសម្រួលសំណើ E208, E208/2 និង E96/8 ដោយយោងទៅលើសេចក្តីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងគោលដៅធានាបាននូវប្រសិទ្ធភាពនៃសវនាការ ដើម្បីទុកលទ្ធភាពឱ្យមេធាវីការពារក្តីអាចលើកការជំទាស់ទៅនឹងឯកសារទាំងនេះបាន។ ជាការឆ្លើយតប សហព្រះរាជអាជ្ញាចោទប្រកាន់ថាមេធាវីការពារជនជាប់ចោទ ខៀវ សំផន បញ្ជាក់ពុំបានត្រឹមត្រូវអំពីទំហំនៃបន្ទុកការងារបកប្រែឯកសារ ដែលសំណើរបស់សហព្រះរាជអាជ្ញាបានដាក់ ហើយសហព្រះរាជអាជ្ញាយល់ឃើញថាមេធាវីការពារក្តីពុំបានប្រើប្រាស់ពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យមើលចម្លើយទាំងនោះ។ មេធាវីការពារក្តីក៏បានបដិសេធថាពុំមានឯកសារណាមួយនៃឯកសារទាំងនេះ ពាក់ព័ន្ធទៅនឹងវិសាលភាពនៃសំណុំរឿង ០០២/០១ ឡើយ ឬពុំចាំបាច់ត្រូវការពេលវេលាច្រើនដើម្បីស្តាប់សេចក្តីជំទាស់ទៅនឹងឯកសារនេះ នោះដែរ (ឯកសារ E223/1)។

៩. ការព្រួយបារម្ភដែលមេធាវីការពារជនជាប់ចោទ ខៀវ សំផន បានលើកពាក់ព័ន្ធនឹងវិការៈដែលត្រូវបានចោទប្រកាន់នៅក្នុងការស្តាប់ចម្លើយសាក្សីដោយអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ត្រូវបានចាត់ការកាលពីពេលមុនរួចហើយនៅក្នុងសេចក្តីសម្រេច E142/3 ហើយនឹងត្រូវបានលើកឡើងដើម្បីតបទៅនឹងសំណើស្រដៀងគ្នាមួយចំនួន ដែលកំពុងស្ថិតនៅចំពោះមុខអង្គជំនុំ

ជម្រះនាពេលបច្ចុប្បន្ន។ បន្ទាប់ពីបានពិនិត្យមើលឡើងវិញទៅលើសារណាសេសសល់របស់ភាគី អង្គជំនុំជម្រះកត់សម្គាល់ឃើញថាសហព្រះរាជអាជ្ញាពុំទាន់បានកាត់បន្ថយឱ្យបានច្រើននូវចំនួននៃចម្លើយដែលសហព្រះរាជអាជ្ញាបានដាក់មកអង្គជំនុំជម្រះសាលាដំបូងឡើយ បើទោះបីជាមានការស្នើសុំឱ្យកាត់បន្ថយចំនួននៃចម្លើយទាំងនោះក៏ដោយ។ ថ្វីបើផលប៉ះពាល់ជាក់លាក់ទៅលើផ្នែកបកប្រែភាសាចំពោះការដាក់ចម្លើយទាំងអស់ដែលសហព្រះរាជអាជ្ញានៅពុំទាន់ត្រូវបានកំណត់ជាក់លាក់ក៏ដោយ ក៏វាជាការដាក់បន្ទុកបន្ថែមទៅអង្គភាពបកប្រែភាសា និងអង្គជំនុំជម្រះដោយជៀសពុំផុតឡើយ។ ដើម្បីអនុញ្ញាតឱ្យមានការជំទាស់តទល់ប្រកបដោយប្រសិទ្ធភាពទៅនឹងចម្លើយទាំងនេះ អនុលោមតាមសេចក្តីណែនាំមុនៗរបស់ខ្លួន និងលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងសេចក្តីសម្រេច E96/7 អង្គជំនុំជម្រះសូមជូនដំណឹងទៅសហព្រះរាជអាជ្ញាថាមានតែចម្លើយទាំងឡាយណាដែលអាចមានជាភាសាផ្លូវការទាំងអស់នៅ អ.វ.ត.ក ត្រឹមថ្ងៃ សុក្រ ទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ប៉ុណ្ណោះ ដែលអាចស្នើសុំដាក់ជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។ សហព្រះរាជអាជ្ញាត្រូវបានណែនាំឱ្យសហការជាមួយអង្គភាពបកប្រែភាសាដើម្បីបញ្ជាក់ថាតើចម្លើយណាខ្លះ ដូចមានកំណត់អត្តសញ្ញាណក្នុងឯកសារ E208, E208/2 និង E96/8 ដែលអាចមានជាភាសាផ្លូវការទាំងអស់នៅ អ.វ.ត.ក ត្រឹមកាលបរិច្ឆេទខាងលើ និងជូនដំណឹងមកអង្គជំនុំជម្រះ និងភាគីឱ្យបានឆាប់បំផុត ប្រសិនបើបន្ទាប់ពីមានការពិគ្រោះយោបល់ជាមួយអង្គភាពបកប្រែភាសា ចម្លើយមួយចំនួនដែលសហព្រះរាជអាជ្ញាបានកំណត់អត្តសញ្ញាណថាលែងចាំបាច់សម្រាប់ដាក់ជាភស្តុតាង។ នៅពេលមានជាភាសាផ្លូវការទាំងអស់នៅ អ.វ.ត.ក អង្គជំនុំជម្រះនឹងដាក់លេខសម្គាល់ E3 ទៅចម្លើយទាំងនេះ និងពិចារណាចម្លើយទាំងនេះ ដោយយោងទៅតាមគោលការណ៍នីត្យានុ- កូលដូចមានចែងក្នុងសេចក្តីសម្រេច E96/7 របស់ខ្លួន។

១០. ការខ្វះខ្នែងរបស់អង្គជំនុំជម្រះដើម្បីអនុញ្ញាតឱ្យមេធាវីការពារក្តីជំទាស់ទៅនឹងឯកសារដែលត្រូវបានដាក់ដោយអនុលោមតាមសេចក្តីសម្រេច E96/7 របស់ខ្លួនត្រូវបានរាំងស្ទះបន្ថែមទៀត ដោយសហមេធាវីនាំមុខពុំបានអនុវត្តតាមសេចក្តីណែនាំដូចមានក្នុងកថាខណ្ឌ៣៥ នៃសេចក្តីសម្រេចនោះ។

១១. ខុសពីសហព្រះរាជអាជ្ញា ដែលយ៉ាងហោចណាស់ផ្តល់ការបញ្ជាក់អំពីបំណងនៃការប្រើប្រាស់ចម្លើយជាលាយលក្ខណ៍អក្សរមួយចំនួន ដែលសហព្រះរាជអាជ្ញាបានដាក់ សហមេធាវីនាំមុខ

សង្កត់ធ្ងន់ទៅលើភាពលម្អិតជាក់លាក់នៃចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសម្រេចស្តីពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមុនៗ ទាក់ទិននឹងចម្លើយទាំងនោះ ដើម្បីផ្តល់ភាពសមហេតុផលដល់ការបដិសេធពុំព្រមផ្តល់ព័ត៌មានដែលអង្គជំនុំជម្រះស្នើសុំ ឬពុំព្រមកាត់បន្ថយចំនួននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលសហមេធាវីនាំមុខមានបំណងដាក់ជាភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E208/4)។ សហមេធាវីនាំមុខបានអះអាងទៀតថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គឺជាចម្លើយរបស់ភាគីមួយនៃរឿងក្តី (ហើយដូច្នេះ ពុំអាចដកចេញពីកិច្ចពិភាក្សាដេញដោលបានឡើយ)។ បើទោះបីជាសហមេធាវីនាំមុខបានគូសបញ្ជាក់នៅពេលក្រោយមកទៀតថាពួកគាត់ "រក្សាសិទ្ធិ" ក្នុងការដាក់គំរូនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះក៏ដោយ (ឯកសារ E208/4, កថាខណ្ឌ ៤៣, កំណត់សម្គាល់ទូទៅ, កថាខណ្ឌ ឃ) ក៏ប៉ុន្តែនៅក្នុងឯកសារដែលសហមេធាវីនាំមុខដាក់នោះ សហមេធាវីនាំមុខពុំបានបញ្ជាក់ថាចម្លើយណាខ្លះស្ថិតនៅក្នុងប្រភេទចម្លើយគំរូ ឬពុំបានផ្តល់ការបញ្ជាក់ផ្សេងៗណាមួយដូចដែលអង្គជំនុំជម្រះបានស្នើសុំក្នុងកថាខណ្ឌ ៣៥ នៃសេចក្តីសម្រេច E96/7 ឡើយ។ លើសពីនេះទៀត សហមេធាវីនាំមុខបានស្នើសុំការពន្យារពេលចំនួនពី ០១ ខែ ទៅ ០២ ខែ ដើម្បីដាក់សេចក្តីសន្និដ្ឋានពាក់ព័ន្ធនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី ១ និងទី ២) ដែលសហមេធាវីនាំមុខមានបំណងដាក់ជាភស្តុតាង (ឯកសារ E208/4, កំណត់សម្គាល់ទូទៅ, កថាខណ្ឌ ង)។

១២. អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា អង្គជំនុំជម្រះពុំបានសម្រេចលើការកំណត់ប្រភេទគតិយុត្តនៃចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬលទ្ធភាពទទួលយកពាក្យសុំរបស់ពួកគាត់នៅក្នុងសេចក្តីសម្រេច E96/7 ឡើយ។ សហមេធាវីនាំមុខយល់ឃើញត្រឹមត្រូវថាការសម្រេចនេះគឺជាសមត្ថកិច្ចរបស់សហចៅក្រមស៊ើបអង្កេតក្នុងអំឡុងដំណាក់កាលមុនសវនាការ។ ជំនួសមកវិញ សេចក្តីសម្រេច E96/7 លើកឡើងអំពីការពិតជាក់ស្តែងមួយចំនួន និងការពិចារណាអំពីការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដែលចេញមកពីផលវិបាកនៃការដាក់ជាភស្តុតាងនូវឯកសារចម្លើយជាលាយលក្ខណ៍អក្សរ ឬពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងចំនួនដ៏ច្រើនសន្ធឹកសន្ធាប់នៅចំពោះមុខអង្គជំនុំជម្រះ ភ្ជាប់ជាមួយសេចក្តីសម្រេចនេះ ដោយពុំមានសក្ខីកម្មរបស់ម្ចាស់ចម្លើយ ឬម្ចាស់ពាក្យសុំ។ បញ្ហានេះខុសប្លែកពីបញ្ហាស្តីពីលទ្ធ

00854297

E223/2

ភាពនៃការទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណី។ ហេតុដូច្នេះ អនុ-លោមតាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងត្រង់កថាខណ្ឌ ៣៥ នៃសេចក្តីសម្រេច E96/7 នោះ វាជាបុរេលក្ខខណ្ឌសម្រាប់ពិចារណាទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដើម្បីដាក់ជាភស្តុតាងក្នុងសំណុំរឿង ០០២/០១ តាមហេតុផលដូចខាងក្រោម៖

- ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមានចំនួនច្រើនរហូតដល់ ៣៨៦៦ ពុំទាន់បកប្រែនៅឡើយទេ។ អង្គភាពបកប្រែភាសាបានជូនដំណឹងថាធនធានរបស់ខ្លួនពុំគ្រប់គ្រាន់ដើម្បីធានាបានថាពាក្យសុំទាំងអស់ អាចត្រូវបានបកប្រែក្នុងអំឡុងអាណត្តិរបស់ អ.វ.ត.ក ឡើយ។ ដោយហេតុថាការដាក់ភស្តុតាងទាំងអស់នៅសវនាការតម្រូវឱ្យភស្តុតាងនោះមានជាភាសាផ្លូវការទាំងអស់នៅ អ.វ.ត.ក សហមេធាវីនាំមុខត្រូវបានណែនាំឱ្យកែសម្រួលចំនួននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលសហមេធាវីនាំមុខមានបំណងដាក់ ដោយពិគ្រោះជាមួយអង្គភាពបកប្រែភាសា ដើម្បីធានាបានថាមានតែពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណា ដែលមានជាភាសាផ្លូវការទាំងអស់នៅ អ.វ.ត.ក ត្រឹមថ្ងៃ សុក្រ ទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ប៉ុណ្ណោះ ដែលនឹងត្រូវបានស្នើសុំដាក់ជាភស្តុតាង។
- ដោយហេតុពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ពុំអាចត្រូវបានដាក់ជាភស្តុតាងក្នុងសំណុំរឿង ០០២/០១ ទើបជាការចាំបាច់ដែលសហមេធាវីនាំមុខត្រូវបញ្ជាក់ថាតើចម្លើយណាខ្លះដែលសហមេធាវីនាំមុខមានបំណងស្នើសុំដាក់ជាភស្តុតាងជាស្ថាពរ ដើម្បីអនុញ្ញាតឱ្យមានការលើកទឡ្ហីករណ៍តទល់ ទាក់ទងនឹងចម្លើយទាំងនេះ។ ដោយហេតុថាអនុលោមតាមក្របខណ្ឌគតិយុត្តនៅ អ.វ.ត.ក ភាគីពុំអាចលើកភស្តុតាងណាមួយប្រឆាំងនឹងជនជាប់ចោទ ប្រសិនបើភស្តុតាងនោះមិនទាន់បានឆ្លងកាត់ការលើកទឡ្ហីករណ៍តទល់។ អាស្រ័យហេតុនេះ ការកំណត់អត្តសញ្ញាណឱ្យបានត្រឹមត្រូវនៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលសហមេធាវីនាំមុខមានបំណងដាក់ជាភស្តុតាង គឺជាបុរេលក្ខខណ្ឌចាំបាច់នៃការដាក់ពាក្យសុំទាំងនោះនៅចំពោះអង្គជំនុំជម្រះ។

១៣. បើទោះបីជាយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងនឹងផ្តល់ពេលវេលាបន្ថែមទៅសហមេធាវីនាំមុខរហូតដល់ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដើម្បីឱ្យសហមេធាវីនាំមុខបញ្ជាក់ថាតើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីណាខ្លះ ដែលជាពាក្យសុំតាំងខ្លួនមានលក្ខណៈគំរូ ដែលសហមេធាវីនាំមុខមានបំណងដាក់ជាភស្តុតាង (ទាក់ទងនឹងចំណុចអង្គហេតុទាំងអស់ដែលត្រូវធ្វើសវនាការក្នុងសំណុំរឿង ០០២/០១) បន្ថែមពីលើព័ត៌មានផ្សេងៗទាំងអស់ដែលអង្គជំនុំជម្រះបានស្នើសុំនៅក្នុងសេចក្តីសម្រេច E96/7 កថាខណ្ឌ ៣៥។ ការខកខានពុំបានធ្វើដូច្នេះ នឹ

ងធ្វើឱ្យអង្គជំនុំជម្រះចាត់ទុកថាសហមេធាវីនាំមុខពុំស្នើសុំដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាភស្តុតាងឡើយ។

១៤. អនុលោមតាមកថាខណ្ឌ ៣៦ នៃសេចក្តីសម្រេច E96/7 និងក្នុងករណីដែលភាគីមានបំណងលើកការជំទាស់ទៅនឹងឯកសារណាមួយដែលត្រូវបានដាក់ ដោយអនុលោមតាមសេចក្តីសម្រេចនេះ ភាគីអាចធ្វើដូច្នេះតាមការស្នើសុំជាលាយលក្ខណ៍អក្សរនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធី ប៉ុន្តែមិនឱ្យហួសថ្ងៃ សុក្រ ទី ២៦ ខែ មេសា ឆ្នាំ ២០១៣ ឡើយ។ អង្គ-ជំនុំជម្រះនឹងថ្លឹងថ្លែងសេចក្តីជំទាស់ទាំងនេះ នៅពេលពិចារណាអំពីឯកសារដែលភាគីបានដាក់ដោយអនុលោមតាមលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងសេចក្តីសម្រេច E96/7។

១៥. ទាំងនេះគឺជាចម្លើយជាផ្លូវការរបស់អង្គជំនុំជម្រះតបទៅនឹងសំណើ E208/4 និងផ្នែកទាំង-ឡាយនៃសំណើ E223 និងសំណើ E223/1 ពាក់ព័ន្ធនឹងភស្តុតាងដែលត្រូវបានដាក់បន្ទាប់ពីមានសេចក្តីសម្រេច E96/7។